# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១ នៅធនាគារជាតិនៃកម្ពុជា មានរៀបចំកិច្ចប្រជុំទ្វេភាគី រវាងធនាគារសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង **ឯកឧត្តម Somphao PHAYSITH** ទេសាភិបាលធនាគារសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យធនាគារ ។

គណៈប្រតិភូធនាគារកណ្តាលទាំងពីរបានប្រជុំ ពិភាក្សា ផ្លាស់ប្តូរយោបល់គ្នា អស់រយៈពេលជាងមួយម៉ោង អំពីព័ត៌មានសេដ្ឋកិច្ច បទពិសោធន៍ក្នុងការដឹកនាំនយោបាយរូបិយវត្ថុ ការគ្រប់គ្រងធនាគារកណ្តាល ការពង្រឹងសេវាទូទាត់នៃប្រទេសទាំងពីរតាមរយៈប្រព័ន្ធធនាគារ ការត្រួតពិនិត្យធនាគារ ការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកបណ្តុះបណ្តាលធនធានមនុស្សតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចសិក្សា និងសិក្ខាសាលា ឬកិច្ចប្រជុំបច្ចេកទេស ជាដើម ។

កិច្ចប្រជុំនេះ ជាវេទិកាសម្រាប់ឱ្យមន្ត្រីបុគ្គលិករបស់ធនាគារកណ្តាលនៃប្រទេសទាំងពីរផ្លាស់ប្តូរព័ត៌មាន និងអ្នកជំនាញការបច្ចេកទេសក្នុងវិស័យធនាគារពង្រឹងកិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីសាមគ្គីភាពនិងភាតរភាពផង និងជាវេទិកាសម្រាប់ពិភាក្សារកដំណោះស្រាយចំពោះបញ្ហាប្រឈមនានា បន្ថែមលើវេទិកាថ្នាក់តំបន់ផង ។

ដោយយល់ឃើញពីផលប្រយោជន៍រួម និងសេចក្តីត្រូវការចាំបាច់របស់ប្រជាជនសម្រាប់ប្រទេសទាំងពីរនៅពេលបច្ចុប្បន្ននិងនៅពេលអនាគត ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ទើបធនាគារជាតិនៃកម្ពុជានិងធនាគារសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ប្រារព្ធពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យធនាគាររវាងប្រទេសទាំងពីរ ។